**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៤៦
ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខៈ ៧០០
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខៈ ៣៥ "ឃ"
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តតាកែវ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៨:៣០ នាទីព្រឹក ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៤៦ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

នាមត្រកូល [redacted] នាមខ្លួន ស្រីទុំ ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] ភាច (ស) ម្តាយឈ្មោះ [redacted] មន (រ) ប្តីឈ្មោះ [redacted] វណ្ណា (លែងលះ) មានកូនចំនួន១នាក់ ជាទីតិជន ទោសពីមុខគ្មាន។

ជាប់ចោទពីបទ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរងរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិព្រៃខ្វារ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ដើមបណ្តឹងឈ្មោះ [redacted] ធារ៉ា ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្ន ភូមិដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។

ដោយមានលោក [redacted] ជាមេធាវីតំណាងឱ្យដើមបណ្តឹង។

ជនរងគ្រោះឈ្មោះ [redacted] អមរិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីលំនៅបច្ចុប្បន្ន ភូមិដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៦៦ ព.ស.ព/២៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញដីកាដំណោះស្រាយលេខៈ ៦១៥ /២០២៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង១០ និង០០នាទី ជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ ភេទស្រី អាយុ ៣៣ឆ្នាំ បានបើករថយន្ត១គ្រឿងម៉ាកកូរ៉ូឡា ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2M-3245 ទិសដៅពីកើតទៅលិច លុះដល់ចំណុចភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ បានបុកជាមួយម៉ូតូ១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ 1AA-2911 បើកបរដោយជនរងគ្រោះឈ្មោះ [redacted] អមរិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ បណ្តាលឱ្យរងរបួសបាក់ជើងខាងឆ្វេង និងរលាត់ដៃជើងទាំងសងខាង។ ក្រោយកើតហេតុឈ្មោះ [redacted] ផារ៉ា ភេទស្រី អាយុ៤៣ឆ្នាំ ត្រូវជាម្តាយរបស់ជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវ ដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្ញុំចេញពីពេទ្យអង្គរកា ទៅផ្ទះយកក្រដាសដោយបើកឡានបានប្រហែល២គីឡូម៉ែត ឡានរបស់ខ្ញុំក៏អស់សាំង (ជិតអស់) ខ្ញុំឃើញកាវ៉ាស់សាំងខ្ញុំក៏បត់ឡានចូលចាក់សាំង ដោយបត់ទៅខាងស្តាំ មិនទាន់ដល់កាវ៉ាស់សាំងផង ឡានក៏រលត់ ហើយឡានខ្ញុំក៏ឈប់ ពេលនោះក៏មានម៉ូតូរបស់ជនរងគ្រោះជិះចេញពីកន្លែងចាក់សាំងមកបុកឡានរបស់ខ្ញុំតែម្តង។ នៅពេលខ្ញុំបើកទ្វារឡានចុះ បន្ទាប់មកខ្ញុំទាមទារយកជនរងគ្រោះទៅមន្ទីរពេទ្យ តែគាត់មិនព្រមទៅទេ ដោយគាត់ថា គាត់ទៅពេទ្យខ្លួនឯង។ ពេលកើតហេតុនោះមានបុគ្គលិកចាក់សាំង និងឈ្មោះ [redacted] ទៀង បានឃើញហេតុការណ៍ដែរ។ មូលហេតុដែលខ្ញុំចូលឡានពីខាងស្តាំដោយមានឡានធំ១គ្រឿងនៅបាំងផ្លូវ ហើយមានទូកាហ្វេដើមបាំង១ទៀត។ ខ្ញុំចេះបើកឡាន១ឆ្នាំហើយ តែខ្ញុំពុំមានប័ណ្ណបើកបរទេ។ ក្រោយកើតហេតុជនរងគ្រោះទាមទារឲ្យខ្ញុំទិញម៉ូតូថ្មី តែខ្ញុំពុំមានលទ្ធភាពទេ។ ខ្ញុំព្យាយាមសម្របសម្រួល តែជនរងគ្រោះពុំព្រម។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផារ៉ា បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្ញុំមិនបានឃើញហេតុការណ៍ផ្ទាល់ទេ ខ្ញុំបានដឹងក្រោយពេលកូនខលប្រាប់។ ពេលខ្ញុំទៅដល់កន្លែងកើតហេតុ ខ្ញុំឃើញកូនកំពុងមានរបួសធ្ងន់ ហើយជនជាប់ចោទសុំសងសំណង បើពុំមានសំណងទេ គាត់សុខចិត្តកាត់ជើងសងវិញ។ ពេលកើតហេតុចប់ទើបឃើញឈ្មោះ [redacted] ទៀង មកដល់ដែរ។ ក្រោយកើតហេតុខ្ញុំទាមទារសំណងចំនួន ៥,០០០$ នៅប៉ូលីសស្រុក តែគាត់មិនឱ្យទេ។ ពេលនេះ ខ្ញុំទាមទារសំណងចំនួន ៤០,០០០,០០០៛។

-ជនរងគ្រោះឈ្មោះ [redacted] អមរិទ្ធ បានឆ្លើយថា: នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩ព្រឹក ខ្ញុំចេញពីសាលា ហើយបានចូលចាក់សាំងចំនួន២លីត្រ ពេលខ្ញុំចូលពុំមានឡានធំនៅបាំងផ្លូវខ្ញុំទេ។ ក្រោយពីចាក់សាំងរួច ខ្ញុំជិះម៉ូតូចេញតាមច្រកខាងលិច ហើយបានប្រហែល១០ម៉ែត្រ មានឡាន១គ្រឿងបើកចូលមក ហើយម៉ូតូរបស់ខ្ញុំក៏បុកប៉ះជាមួយឡានពីខាងមុខផ្នែកខាងឆ្វេង ពេលបុកហើយឡានរុញទៅមុខបន្តិចបន្តួច ដោយម៉ូតូរបស់ខ្ញុំជាប់នៅខាងក្រោមឡាន តែខ្ញុំពុំដឹងថាឡាននោះមានល្បឿនប៉ុន្មានទេ។ ឈ្មោះ [redacted] ទៀង ខ្ញុំពុំដឹងគាត់មកពេលណាទេ។ ក្រោយកើតហេតុពុំមានសមត្ថកិច្ចមកទេ ហើយខ្ញុំក៏ពុំបានប្តឹងដែរ ដោយសារជនជាប់ចោទសន្យាដោះស្រាយសំណង។ ខ្ញុំព្យាបាលរបួសនៅមន្ទីរពេទ្យខេត្តសៀមរាប។ សព្វថ្ងៃនេះ ខ្ញុំពុំទាន់ជាសះស្បើយទេ។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted] ទៀង បានឆ្លើយថា: នៅថ្ងៃកើតហេតុវេលាម៉ោង១០ព្រឹក ខ្ញុំចេញពីផ្សារអង្គរកា ហើយបានឃើញហេតុការណ៍បុកគ្នា ពេលទៅដល់ឃើញម៉ូតូនៅក្រោមឡានមែន ពេលនោះខ្ញុំបានជួយសម្រុះសម្រួល។ ខ្ញុំពុំបានឃើញហេតុការណ៍ដោយផ្ទាល់ទេ។ ឈ្មោះ ភាព ថាម៉ូតូជិះលឿន។ ពេលកន្លែងគ្រោះថ្នាក់មកកន្លែងចាក់សាំងចម្ងាយប្រហែល ១០ម៉ែត្រ។ ខ្ញុំពុំដឹងថាមានកាមេរ៉ាសុវត្ថិភាពឬអត់ទេ។

**មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា** ឆ្លងតាមសវនាការថ្ងៃនេះឃើញថាជនជាប់ចោទមិនបានបង្ហាញចេតនាពិតទេ ហើយជនជាប់ចោទបានបើកបរដោយពុំមានប័ណ្ណបើកបរ។ ហេតុនេះសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរ និងទាមទារសំណងឱ្យកូនក្តីខ្លួនចំនួន ៤០,០០០,០០០៛ដោយអនុគ្រោះ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទបានទទួលកំហុស តែជនជាប់ចោទបើកបរដោយពុំមានប័ណ្ណបើកបរទេ តែផ្អែកតាមអង្គហេតុឃើញថា គូភាគីមានចេតនាចង់សម្របសម្រួល។ ហេតុនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដដែល និងសុំឱ្យលោកចៅក្រមពិចារណា និងសម្រេចទៅតាមច្បាប់។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា** កូនក្តីខ្លួនបត់ឡានចូលចាក់សាំង ហើយពេលមានម៉ូតូមកបុក គឺឡានឈប់ហើយ ហើយកូនក្តីខ្លួនពុំមានចេតនាក្នុងរឿងហេតុនេះទេ។ កូនក្តីពុំមានចេតនាគេចវេសទេ ហើយនៅតែមានចេតនា សងជាសំណងទៅជនរងគ្រោះដដែល ដូចដែលមានតម្កល់ប្រាក់ទុកនៅតុលាការរួចហើយ។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ បានសំណូមពរថា សូមឱ្យតុលាការជួយសម្រាលទោសដល់ខ្ញុំផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>សំអាងហេតុ</u>**

១.កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ស្ថិតនៅភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវពិតជាមានករណីបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ ប្រាកដមែន។



Scanned with CamScanner

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនចេញពីពេទ្យអង្គរកាទៅផ្ទះយកក្រដាស ដោយបើកឡានបានប្រហែល២គីឡូម៉ែត ឡានរបស់ខ្លួនក៏អស់សាំង (ជិតអស់) ខ្លួនឃើញការ៉ាស់សាំងខ្លួនក៏បត់ឡានចូលចាក់សាំង ដោយបត់ទៅខាងស្តាំ មិនទាន់ដល់ការ៉ាស់សាំងផង ឡានក៏រលត់ ហើយឡានខ្លួនក៏ឈប់ ពេលនោះក៏មានម៉ូតូរបស់ជនរងគ្រោះជិះចេញពីកន្លែងចាក់សាំងមកបុកឡានរបស់ខ្លួនតែម្តង។ នៅពេលខ្លួនបើកទ្វារឡានចុះ បន្ទាប់មកខ្លួនទាមទារយកជនរងគ្រោះទៅមន្ទីរពេទ្យ តែគាត់មិនព្រមទៅទេ ដោយគាត់ថា គាត់ទៅពេទ្យខ្លួនឯង។ ពេលកើតហេតុនោះមានបុគ្គលិកចាក់សាំង និងឈ្មោះ [redacted] ទៀង បានឃើញហេតុការណ៍ដែរ។ មូលហេតុដែលខ្លួនចូលឡានពីខាងស្តាំដោយមានឡានធំ១គ្រឿងនៅបាំងផ្លូវ ហើយមានទូកាហ្វេដើមបាំង១ទៀត។ ខ្លួនចេះបើកឡាន១ឆ្នាំហើយ តែខ្លួនពុំមានប័ណ្ណបើកបរទេ។ ក្រោយកើតហេតុជនរងគ្រោះទាមទារឱ្យខ្លួនទិញម៉ូតូថ្មី តែខ្លួនពុំមានលទ្ធភាពទេ។ ខ្លួនព្យាយាមសម្របសម្រួល តែជនរងគ្រោះពុំព្រម។ ការឆ្លើយបដិសេធរបស់ជនជាប់ចោទនេះគ្រាន់តែជាលេសដោះសារដើម្បីឱ្យរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ព្រោះនៅថ្ងៃកើតហេតុឡានរបស់ជនជាប់ចោទជិតអស់សាំង ដែលធ្វើឱ្យជនជាប់ចោទមានជិតភ័យ ហើយក៏បើកឡាននោះបត់ចូលការ៉ាស់សាំងដែលនៅក្បែរនោះយ៉ាងគគ់ក្រហាល់ ទើបបណ្តាលឱ្យបុកជាមួយជនរងគ្រោះតែម្តង។ ម្យ៉ាងវិញទៀត តាមរូបភាពដែលមាននៅក្នុងសំណុំរឿងមានលក្ខណៈផ្ទុយពីចម្លើយដែលជនជាប់ចោទបានគ្រង់ជនជាប់ចោទបញ្ជាក់ថា មូលហេតុដែលខ្លួនពុំបានជិះចូលការ៉ាស់សាំងនៅផ្លូវបត់ចូលទី១ ដោយសារតែមានឡានធំមួយគ្រឿងចតនៅទីនោះ ប៉ុន្តែពិនិត្យតាមរូបភាពដែលថតបាននៅក្នុងសំណុំរឿង គឺមិនមានឡាននោះទេ។

៣.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធារ៉ា បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនមិនបានឃើញហេតុការណ៍ផ្ទាល់ទេ ខ្លួនបានដឹងក្រោយពេលកូនខលប្រាប់។ ពេលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនឃើញកូនកំពុងមានរបួសធ្ងន់ ហើយជនជាប់ចោទសុំសងសំណង បើពុំមានសំណងទេ គាត់សុខចិត្តកាត់ជើងសងវិញ។ ពេលកើតហេតុចប់ទើបឃើញឈ្មោះ [redacted] ទៀង មកដល់ដែរ។ ក្រោយកើតហេតុខ្លួនទាមទារសំណងចំនួន ៥,០០០$ នៅប៉ូលិសស្រុក តែគាត់មិនឱ្យទេ។ ពេលនេះ ខ្លួនទាមទារសំណងចំនួន ៤០,០០០,០០០៛។ តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនេះ បង្ហាញឱ្យឃើញថា នៅពេលកើតហេតុគឺដើមបណ្តឹងពុំបាននៅកន្លែងកើតហេតុនោះទេ ហើយគ្រាន់តែដឹងរឿងហេតុដោយអ្នកជិតខាងប្រាប់តែប៉ុណ្ណោះ។

៤.តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] អមរិទ្ធ បានឆ្លើយថា: នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩ព្រឹក ខ្លួនចេញពីសាលា ហើយបានចូលចាក់សាំងចំនួន២លីត្រ ពេលខ្លួនចូលពុំមានឡានធំនៅបាំងផ្លូវខ្លួនទេ។ ក្រោយពីចាក់សាំងរួច ខ្លួនជិះម៉ូតូចេញតាមច្រកខាងលិច ហើយបានប្រហែល១០ម៉ែត្រ មានឡាន១គ្រឿងបើកចូលមកហើយម៉ូតូរបស់ខ្លួនក៏បុកប៉ះជាមួយឡានពីខាងមុខផ្នែកខាងឆ្វេង ពេលបុកហើយឡានអូសរុញទៅមុខបន្តិចបន្តួចដោយម៉ូតូរបស់ខ្លួនជាប់នៅខាងក្រោមឡាន តែខ្លួនពុំដឹងថាឡាននោះមានល្បឿនប៉ុន្មានទេ។ ឈ្មោះ [redacted] ទៀង ខ្លួនពុំដឹងគាត់មកពេលណាទេ។ ក្រោយកើតហេតុពុំមានសមត្ថកិច្ចមកទេ ហើយខ្លួនក៏ពុំបានប្តឹងដែរ ដោយសារជនជាប់ចោទសន្យាដោះស្រាយសំណង។ ខ្លួនព្យាបាលរបួសនៅមន្ទីរពេទ្យខេត្តសៀមរាប។ សព្វថ្ងៃនេះ ខ្លួនពុំទាន់ជាសះស្បើយទេ។



Scanned with CamScanner

តាមចម្លើយសាក្សីនេះ បញ្ជាក់ឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ ដូចការចោទប្រកាន់របស់តំណាងអយ្យការ ប្រាកដមែន។

៥.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ទៀង បានឆ្លើយថា: នៅថ្ងៃកើតហេតុវេលាម៉ោង១០ព្រឹក ខ្លួនចេញពីផ្សារអង្គរកា ហើយបានឃើញហេតុការណ៍បុកគ្នា ពេលទៅដល់ឃើញម៉ូតូនៅក្រោមឡានមែន ពេលនោះខ្លួនបានជួយសម្រុះសម្រួល។ ខ្លួនពុំបានឃើញហេតុការណ៍ដោយផ្ទាល់ទេ។ ឈ្មោះ ភាព ថាម៉ូតូជិះលឿន។ ពេលកន្លែងគ្រោះថ្នាក់មកកន្លែងចាក់សាំងចម្ងាយប្រហែល ១០ម៉ែត្រ។ ខ្លួនពុំដឹងថាមានការមេរ៉ាសុវត្ថិភាពឬអត់ទេ។ តាមចម្លើយសាក្សីនេះបង្ហាញឱ្យឃើញថា នៅពេលកើតហេតុគឺសាក្សីពុំបាននៅកន្លែងកើតហេតុនោះទេ។

៦.ជនជាប់ចោទជានីតិជន ដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌបាន ពោលគឺជនជាប់ចោទពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។

៧.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីការបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នធ្វើឱ្យរបួសអ្នកដទៃ គឺជាអំពើល្មើស ដែលច្បាប់តម្រូវឱ្យធ្វើការផ្ដន្ទាទោស។

៨.អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយរបស់អ្នកដទៃ, របៀបរៀបរយសាធារណៈ សន្តិសុខសង្គម ដែលច្បាប់ការពារ។

៩.ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ ដូចនេះគប្បីតុលាការ ពិចារណាទៅលើរបបប្រកាសទោសពាក់កណ្ដាលជាមួយការព្យួរទោសតាមបញ្ញត្តិមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

១០.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារ៉ា បានប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ៤០,000,000៛ (សែសិបលាន) រៀល ដូច្នេះ គប្បីតុលាការពិចារណាអំពីការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្របទៅនឹងព្យសនកម្មជាក់ស្ដែង ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង។

១១.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រីទុំ ពីបទ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិព្រៃខ្វាវ ស្រុកត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

១២.មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា: ឆ្លងតាមសវនាការថ្ងៃនេះឃើញថាជនជាប់ចោទមិនបានបង្ហាញចេតនាពិតទេ ហើយជនជាប់ចោទបានបើកបរដោយពុំមានប័ណ្ណបើកបរ។ ហេតុនេះសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់ធ្ងរ និងទាមទារសំណងឱ្យកូនក្ដីខ្លួនចំនួន ៤០,000,000៛ ដោយអនុគ្រោះ។ ការស្នើសុំនេះ គប្បីតុលាការពិចារណា។

១៣.ការស្នើសុំរបស់តំណាងអយ្យការ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទបានទទួលកំហុស តែជនជាប់ចោទបើកបរដោយពុំមានប័ណ្ណបើកបរទេ តែផ្អែកតាមអង្គហេតុឃើញថា គូភាគីមានចេតនាចង់សម្របសម្រួល។ ហេតុនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដដែល និងសុំឱ្យលោក



Scanned with CamScanner

ចៅក្រមពិចារណា និងសម្រេចទៅតាមច្បាប់។ ការស្នើសុំនេះ មានលក្ខណៈត្រឹមត្រូវ ព្រោះមានពិរុទ្ធភាពគ្រប់គ្រាន់គប្បីតុលាការពិចារណា។

១៤.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីខ្លួនបត់ឡានចូលចាក់សាំង ហើយពេលមានម៉ូតូមកបុក គឺឡានឈប់ហើយ ហើយកូនក្ដីខ្លួនពុំមានចេតនាក្នុងរឿងហេតុនេះទេ។ កូនក្ដីពុំមានចេតនាគេចវេសទេ ហើយនៅតែមានចេតនា សងជាសំណងទៅជនរងគ្រោះដដែល ដូចដែលមានតម្កល់ប្រាក់ទុកនៅតុលាការរួចហើយ។ ការស្នើសុំនេះ គប្បីតុលាការពិចារណា។

## **<u>ហេតុដូច្នេះសម្រេច</u>**

១/.ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ស្រីទុំ** ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ) ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរ ពីបទ៖ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

២/.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ស្រីទុំ** សងសំណងជំងឺចិត្តឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឆារ៉ា** ចំនួន **១៥,០០០,០០០៛ (ដប់ប្រាំលាន)** រៀល។ ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ, ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ, ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជីសវនាការ** |
|---|---|
| [redacted] | [redacted] |



Scanned with CamScanner